# ៣ - ប្រពៃណីអ្នកស្រុកចេនលា

## ១៣. អំពីពេលបុណ្យចូលឆ្នាំ

គេយកខែទីត១០ របស់ចិនធ្វើខែទី១ ហើយខែនោះមានឈ្មោះថាកាតិក (កក្ដិក)(១)។ នៅពីមុខវាំងគេសង់វេទិការមួយយ៉ាងធំ ដែលអាចដាក់បានមនុស្សមួយពាន់នាក់ ហើយគេចងប្រទីបផ្ងាលា និងផ្កាផ្ទីជាដើម លំអនៅលើថ្នាក់នោះ។ នៅពីមុខដែលឃ្លាតពីទីនេះប្រមាណជា ២០០ហត្ថ មានទីលានមួយទៀត គេបន្តឈើធ្វើជារោងរន្ទា ដែលមានកំពល់ដល់ទៅជាង២០០ហត្ថ។ ក្នុងយប់នោះគេអុជកាំជ្រួច រន្ទា ផាវបី-បួន រឺ ប្រាំកន្លែង។ នៅក្នុងរោងនោះ ស្ដេចក៏យាងចេញមកទត កាំជ្រួច រន្ទា និង ផាវ ដែលគេអុជនៅខាងក្រៅចំងាយ ១០០លី តែគេអាចមើលឃើញ និងស្ដាប់សូរយ៉ាងច្បាស់ លឺខ្លាំងមើលតែកាំភ្លើងធំទ្រហឹងខ្ទរខ្ទារពេញតែទីក្រុង។

១ = បានជារាប់ពីខែកក្ដិត ព្រោះជំនាន់ដើមគេរាប់រនោចមុនខ្នើត គឺពី១រោចខែកក្ដិក ទៅជាដើមឆ្នាំខែលេខ ១។

មន្ត្រីនិងរាជវង្សទាំងអស់នាំគ្នាកាន់ទៀន និងម្លូស្លាដែលជាហេតុនាំអោយចំនាយប្រាក់យ៉ាងច្រើន។ នៅក្នុងពិធីនេះ ស្ដេចបានអញ្ជើញពួកទូតបរទេសទៅចូលរួមផងដែរ។ គេធ្វើដូចនេះអស់រយៈពេលកន្លះខែទើបបានចប់។
នៅក្នុងខែនិមួយៗ សុទ្ធតែមានពិធីបុណ្យដែរ ដូចជានៅខែទី៤ គេបោះឈូង ខែទី៩ ធ្វើអ៊ាបឡាក់(២) ពិធីនេះគេហៅប្រជុំមនុស្សចូលក្រុង ហើយហាត់ក្បួនដើរដង្ហែកាត់មុខវាំង។ ខែទី៥ គេទទួលយកទឹកមន្តព្រះពុទ្ធ ពីគ្រប់ទីជិតឆ្ងាយទាំងអានាចក្រ យកមកស្រោចស្រង់ថ្វាយព្រះរាជជំរះកាយ ហើយអុំនាវានៅលើគោក (អុំទូកគោក) អែស្ដេចយាងឡើងលើប្រាសាទទតមកពិធីនេះ។ ខែទី៧ ធ្វើពិធីដុតភ្នំស្រូវ។ ពេលនោះស្រូវទើបនឹងទុំថ្មី គេទទួលយកមកតាមទ្វារខាងត្បូង ហើយគេគរដុត ថាជាការបូជាចំពោះព្រះពុទ្ធ។ មានស្រីៗច្រើនណាស់ជិះរទេះ រឺ ដំរី នាំគ្នាមកមើលពិធីនេះ អែព្រះរាជាមិនចេញមកទតពិធីនេះទេ ទ្រង់គង់នៅអែព្រះដំនាក់។ ខែទី៨ ធ្វើពិធីអែលាំ(៣) ពិធីនេះគេរាំរែក។ គេចាត់អ្នករាំនិងអ្នកភ្លេងពូកែៗអោយចូលទៅរាំអែលាំក្នុងវាំងរាល់ៗថ្ងៃ។ ក្រៅពីនេះមានប្រជល់ជ្រូក និងប្រជល់ដំរីទៀត។ ពិធីនេះស្ដេចក៏អញ្ជើញពួកទូតប្រទេសក្រៅចូលទស្សនាផងដែរ។ គេធ្វើដូច្នេះរហូតដល់គ្រប់ដប់ថ្ងៃ។ អែដទៃទៀត ខ្ញុំមិនបានកត់ត្រាអោយច្បាស់លាស់ទេ។ អ្នកស្រុកនេះ ក៏មានអ្នកចេះវិជ្ជាតារាសាស្ត្រដូចចិនដែរ អាចនឹងដេញរកថ្ងៃខែណាធំតូច រឺ សូរ្យគ្រាស ចន្ទគ្រាសដែរ តែថ្ងៃខែធំតូចនេះ មិនដូចគ្នានឹងប្រទេសចិនទេ។ បើឆ្នាំណាជាឆ្នាំអធិកមាស គេក៏មានលើកខែដែរ។ ខែដែលត្រូវលើកនោះគឺខែទី៩(៤) ប៉ុន្តែខ្ញុំមិនដឹងការនេះសព្វគ្រប់ទេ។ ក្នុង១យប់ គេចែកចេញជាប្រាំយាម។ ប្រាំពីរថ្ងៃរាប់ជាមួយជុំ គឺដូចគ្នានៅស្រុកចិន ហៅថា កាយ-ពី-គៀន-ជូ។

២ = លោកប៉េលីយោតប្រែថា Ya-lie ហើយចុះសេចក្ដីយល់ថា Ràp Riep។ ៣ = លោកប៉េលីយោតប្រែថា Gnai-lan (Ràm) ៤ = តាមពិតយើងលើកខែទី៨ គឺខែអាសាធ ប៉ុន្តែនេះ គឺលោកជីវក្វាន់និយាយតាមខ្មែរជំនាន់ដើម ដែលរាប់ពី១រោច ខែអាសាធ ទៅដល់ ១កើតខែស្រាពណ៍ចាត់ជាខែទី៩។

អ្នកស្រុកនេះ គ្មានប្រើនាមត្រកូល(សែ) គ្មានឈ្មោះ ហើយមិនចេះកត់ថ្ងៃខែកំនើតផង ភាគច្រើន គេយកឈ្មោះថ្ងៃដែលកើត ហៅជាឈ្មោះមនុស្ស។ តាមក្បួនយាមថា ក្នុងមួយសប្ដាហ៍ មានពីរថ្ងៃល្អបំផុត បីថ្ងៃល្មមមធម្យ ពីរថ្ងៃអាក្រក់ ហើយថ្ងៃណាត្រូវចេញដំនើរបែរមុខទៅទិបូពិ រឺត្រូវឆ្ពោះទៅទិសបស្ចឹម។ ពួកស្រីៗក៏ចេះរាប់ថ្ងៃខែដែរ។ ឆ្នាំទាំង១២ មានយកសត្វជាជំនាងដូចឆ្នាំរបស់ចិនដែរ តែហៅឈ្មោះខុសគ្នា អុបមាដូចគេហៅឆ្នាំសេះថា ប៉ុកសាយ ឆ្នាំមាន់ហៅ

ថា ឡាក់ ឆ្នាំជ្រូកហៅថា ចេកលូ និងឆ្នាំគោហៅ គូជាដើម។

### ១៤. អំពីការកាត់ក្តី

រឿងប្រជារាស្ត្រក្តីក្តាំគ្នា ពិតមែនតែជាការតូចតាច ប៉ុន្តែជាការមួយគួរអោយចង់ដឹងចង់លឺដែរ។ រឿងក្តីក្តាំរបស់រាស្ត្រ សុទ្ធតែឡើងគាល់រហូតដល់ស្តេចអោយជំរះក្តី។ ដើមឡើយ ស្តេចអិតមានវាយតប់ដោយរំពាត់ធំ រឺ តូចឡើយមានតែពិន័យជាមាសប៉ុណ្ណោះ។ បើអ្នកនោះមានះមិនព្រមធ្វើតាម រឺ មានទោសធ្ងន់នោះ គេចាប់ចងយកទៅប្រហារជីវិតដែរ គ្រាន់តែនាំចេញទៅទ្វារខាងលិច ហើយអោយជីករន្តៅកប់អ្នកទោសនោះ និង យកដី រឺ ថ្មកប់គ្របពីលើប៉ុណ្ណោះ។

ទោសស្រាលបន្ទាប់មក គឺកាត់ម្រាមដៃជើង មានខ្លះត្រូវគេកាត់ច្រមុះចោលក៏មានដែរ។ រឿងសហាយស្មន់ និងលេងល្បែង អិតមានហាមឃាត់ទេ។ បើប្តីរបស់ស្រីដែលមានសហាយនោះដឹង គេយកឈើពីរ ទៅចងគាបជើងរបស់ប្រុសសហាយនោះ អោយឈឺស្ទើរស្លាប់។ បក្សពួកខាងប្រុសទាំងប៉ន្មានត្រូវរួចខ្លួន។ អែអ្នកដែលផ្តើមគំនិតបោកប្រាស់គេត្រូវមានទោសដែរ។ បើមានមនុស្សស្លាប់នៅនឹងទ្វារកំពែង គេយកខ្សែចងអូសទៅទីវាលក្រៅក្រុង ហើយសម័យនោះគ្មានការពិនិត្យសាកសព្វអ្វីទេ។ បើគេចាប់បានចោរក៏អាចនាំទៅឃុំឃាំងសួរចំលើយដែរ តែមានការគួរអោយអស់សំនើច គឺថា បើគេសង្ស័យថាជននោះជាចោរ ហើយជននោះមិនព្រមទទួលសារភាព គេនឹងយកខ្ទះមកដាំខ្លាញ់អោយក្តៅមែនទែន ហើយគេអោយជននោះលូកដៃទៅក្នុងខ្លាញ់កំពុងពុះនោះអែង។ បើជននោះជាចោរមែនក៏ត្រូវរលាករលួយដៃ បើមិនមែនជាចោរទេ អិតមានរលាកឡើយ។ ម្យ៉ាងទៀត បើមានគ្រួសារពីរក្តីក្តាំគ្នា ហើយរកកាត់សេចក្តីរកនរណាត្រង់ រឺ វៀចមិនមិនកើត គេធ្វើដូច្នេះ នៅពីមុខវាំង មានប្រសាទថ្មតូចៗ ១២ខ្នង ហើយគេបញ្ជាកូនក្តីអោយចូលទៅអង្គុយក្នុងប្រសាទនោះមួយម្នាក់។ គេអង្គុយតាំងពីមួយថ្ងៃ ពីរ បី រឺ បួនថ្ងៃទៅ បើនរណាដែលជាអ្នកធ្វើខុសនឹងច្បាប់នោះពិតជាមានភស្តុតាងលេចឡើងមិនខាន គឺបើមិនចេញកមរមាស់ទេ ក៏ក្អក្តៅផ្តាសាយដែរ។ អែអ្នកទៀងត្រង់អិតមានផុលរមាស់អ្វីឡើយ។ ការវិន័ច្ឆ័យដូច្នេះ គេហៅថា គុកសួគ៌។ រឿងដូច្នេះបានមកពីព្រះភូមិរក្សាទឹកដីរបស់គេ ពូកែសក្តិសិទ្ធិណាស់ ទើបគេអាចធ្វើដូច្នេះទៅកើត។

១ =គុកសួគ៌ គឺជាគុកមួយដែលសក្តិសិទ្ធ ដូចទេវតាមកកាត់ក្តីនេះអោយ។

### ១៥. អំពីជំងឺស្រែង(២)

អ្នកស្រុកមានកើតជំងឺស្រែងច្រើនគ្នាណាស់ មកពីគេចូលចិត្តមុជត្រាំក្នុងទឹក ហើយអុស្សាហ៍លាងសក់ក្បាល តែងមានកើតជំងឺស្រែងច្រើនណាស់។ នៅតាមផ្លូវថ្នល់ ពួកនេះមិនសូវអៀនខ្មាសទេ។ ខ្ញុំលឺគេថា ពួកទាំងនេះតែគេរួមរ័កគ្នាភ្លាមគេចុះទៅងូតទឹកហើយ ដូច្នេះតែងមានជំងឺមូល បន្តាលអោយស្លាប់អស់៨-៩នាក់ដែរក្នុងបន្តាមួយពាន់នាក់។ នៅទីផ្សារមានលក់ថ្នាំសំរាប់កែរោគដែរ តែមិនដូចថ្នាំចិនទេ មិនដឹងជាថ្នាំអ្វីឡើយ ថែមទាំងមានគ្រូមន្តអាគមដើរព្យាបាលរោគអោយគេ ជាការគួរអស់សំនើចណាស់។

១ = លោកប៉េលិយោត ប្រែថាឃ្លង់ ប៉ុន្តែតាមន័យអក្សរចិន ប្រែអោយចំគឺស្រែង។ បើថាឃ្លង់ដូចជាមិនមែន ព្រោះកើតឃ្លង់អែណាដល់ទៅពេញស្រុក បើឃ្លង់មែន មិនងាយមើលជាទេ។ បើថាស្រែងនោះសមមែន ព្រោះជំងឺនេះច្រើនបន្តាលមកពីការកខ្វក់។

### ១៦. អំពីមរណភាព

មនុស្សចាស់គេអិតមានដាក់ក្តារមឈូសទេ គេយកតែកន្ទេលក្រាលពីក្រោម យកកំនាត់សំពត់គ្របពីលើ ហើយគេយកទៅព្រៃហើយ។ កាលពីដើម គេក៏ប្រើទង់ព្រលឹង និង ភ្លេងភ្លាត់ហែខ្មោចដែរ ហើយគេលីងលាចពីរមុខ បាចតាមផ្លូវនាំមុខខ្មោច លុះលែងទៅដល់ក្រៅក្រុងដល់កន្លែងស្ងាត់ គេក៏ដាក់ចោលខ្មោចនោះហើយត្រលប់មកវិញ។ បើមានសត្វខ្លែង រឺ តិរច្ឆានអ្វីដទៃទៀតស៊ីខ្មោចនោះអស់មួយរំពេចទៅ គេថាអូវពុកម្តាយនោះ មានភ័ពបានសុខសប្បាយល្អណាស់ តែ

បើគ្មានសត្វស៊ីសោះ រឺ មានស៊ីដែរ តែមិនអស់វិញ គេបែរជាយល់ថា អូវពុកម្តាយនេះ មានពៀរមានទោសទើបបានដូច្នេះ។

លុះមកដល់គ្រាអិល្ងវនេះ មានគេយកខ្មោចទៅដុតបូជាខ្លះៗហើយ។ ពួកអ្នកដែលមានជាប់ពូជជាកូនចិន អូវពុកម្តាយស្លាប់ទៅគេអិតស្លៀកពាក់សកាន់ទុក្ខទេ។ ប្រុសគ្រាន់តែកោរសក់ ក៏ចាត់ជាការកាន់ទុក្ខហើយ។ ចំនែកស្តេចវិញ មានប្រាសាទសំរាប់កប់ ប៉ុន្តែមិនដឹងជាកប់ខ្លួនទាំងមូល រឺ កប់តែឆ្អឹងទេ។

## ១៧. អំពីការភ្ជួរដាំ

ប្រហែលជាក្នុងមួយឆ្នាំ គេអាចសាបព្រោះនិងច្រូតស្រូវបានបី រឺ បួនលើក ពីព្រោះរដូវទាំងបួនមានធាតុអាកាសស្រួលល្អ ដូចជាខែទី ៥ ទី ៦ ដែរ។ ម្យ៉ាងទៀត ស្រុកនេះ គេមិនស្គាល់ដូចម្តេចថាធ្លាក់ព្រិល រឺ ទឹកកកឡើយ។ ស្រុកគេ កន្លះឆ្នាំភ្លៀង កន្លះឆ្នាំអិតមានភ្លៀងសោះ។ ចាប់តាំងពីខែទី៤ ដល់ទី៥ តែដល់ពេលរសៀលមានភ្លៀងធ្លាក់រាល់ថ្ងៃ ទឹកនៅក្នុងសមុទ្រទឹកសាប (ទន្លេសាប) ដោរឡើងមានកំពល់ ៧០ -៨០ ហត្ថ។ ដើមឈើធំៗលិចនៅសល់តែចុង អែពួកអ្នកស្រុករស់នៅក្បែរមាត់ទឹកនោះបាននាំគ្នារើលំនៅមកជ្រកខាងក្រោយភ្នំវិញ។

ចាប់ពីខែទី១០ ដល់ខែទី៣ នៃឆ្នាំថ្មី គ្មានភ្លៀងមួយដំនក់ទេ នៅក្នុងសមុទ្រទឹកសាបនោះ ធ្វើដំនើរបានតែកូននាវាតូចៗទេ។ ត្រង់កន្លែងទឹកជ្រៅ មានជំរៅត្រឹម ៣ រឺ ៥ហត្ថប៉ុណ្ណោះ។ ពេលនោះអ្នកស្រុករើលំនៅទៅនៅមាត់ទឹកធ្វើការភ្ជួរដាំវិញ។ ចំពោះស្រូវ ដល់ទៅពេលណាទុំ ក៏ត្រូវពេលទឹកឡើងដល់ល្មម។ គេសាបព្រោះដាំតាមកន្លែងដីរបស់គេរក្សារៀងខ្លួន។ គេភ្ជួរស្រែដោយមិនបាច់ប្រើគោទេ។ ចប និង កន្ត្រៀវរបស់គេ ពិតមែនតែមានសន្ទានប្រហាក់ប្រហែលគ្នានឹង របស់ចិនដែរ តែមិនដូចគ្នាឡើយ។

មានស្រែព្រៃមួយបែបទៀត គេមិនព្រោះស្រូវធម្មតាទេ ស្រូវដែលគេព្រោះនោះចេះលូតឡើងតាមទឹក បើទឹកឡើងដល់កំពស់ ១០ហត្ថ ក៏ស្រូវលូតឡើងកំពស់នោះដែរ។ នេះប្រហែលជាពូជស្រូវមួយបែបផ្សេងទៀតហើយ។ ស្រែអំពកនិងថ្នាលបន្លែ គេមិនប្រើគ្រឿងស្មោគគ្រោក ដែលជាហេតុនាំអោយមិនស្អាតនោះទេ។ ពួកចិនដែលទៅដល់ស្រុកនោះ ក៏គេមិនហ៊ាននិយាយរឿងពាងលាមកនៅប្រទេសចិនអោយពួកនោះដឹងដែរ ព្រោះខ្លាចគេមើលងាយ។ នៅក្នុងផ្ទះពីរបីខ្នង គេជីករន្តៅបង្គន់អាចម៍មួយហើយគេប្រក់ស្បូវ។ ដល់កាលណាពេញទៅនោះ គេលប់ចោលវិញ ហើយទៅជីករន្តៅមួយទៀត។ ទៅពេលដែលបន្ទោរបង់រួច គេតែងតែចុះទៅលាងអែក្នុងស្រះអោយបានស្អាតជានិច្ច តែគេយកតែដៃឆ្វេងទៅលាងទេ អែដៃស្តាំគេទុកបរិភោគបាយ។ ពួកគេមើលឃើញជនជាតិចិនចូលបង្គន់ហើយយកក្រដាសកិត គេសើចថែមទាំងមិនចង់អោយឡើងលើផ្ទះគេទៀតផង។ ស្រីៗស្រុកនេះ បត់ជើងតូចឈរដូចប្រុសដែរ ជាការគួរអោយអស់សំនើចណាស់។

## ១៨. អំពីទឹកដី

ចាប់តាំងពីចូលក្នុងស្រុក ចេងជូវមក ខ្ញុំមើលឃើញសុទ្ធតែព្រៃឈើវែងអន្លាយ នៅតាមមាត់ទន្លេដ៏ធំធេង មានដើមឈើធំចាស់បុរាណ និង គុម្ពផ្តៅស៊ុបទ្រុបចំងាយរាប់រយលី ហើយមានសំលេងបក្សាបក្សីស្រែទ្រហឹងអឹងកង នៅទីនោះផង។ លុះទៅដល់ពាក់កន្តាលទន្លេ ទើបមើលទៅឃើញវាលស្រែដ៏ធំធេង គ្មានឃើញដើមឈើមួយដើមឡើយ គេមើលទៅឃើញតែស្រូវទុំនៅសព្វទិសទីប៉ុណ្ណោះ។

មានសត្វគោព្រៃរាប់រយរាប់ពាន់ បានមកផ្តុំគ្នាជាហ្វូងនៅទីនោះ។ មានរិស្សីដុះជាប់គ្នាជាដងព្រៃ មានចំងាយរាប់រយលីហើយរិស្សីទាំងនោះមានជូរបន្លានៅគ្រង់គ្រប់ថ្នាំង។ ទំពាំងរិស្សីមានរសជាតិហាងខ្លាំងណាស់ ហើយនិងមានភ្នំនៅគ្រប់ទិសទាំងបួនទៀតផង។

### ១៩. អពីផលានុផល

ស្រុកនេះ មានភ្នំច្រើន និងមានដើមឈើប្លែកៗ។ កន្លែងណាដែលគ្មានដើមឈើទេ គឺជាកន្លែងដែលសត្វរមាសនិងដំរីរស់នៅ។ ពពួកសត្វស្លាបដ៏មានតំលៃ និង សត្វម្រឹគដ៏ប្លែកៗ មានច្រើនអិតគណនា។ មានសត្វចចាតពណ៌ និងពោមល្អិត ភ្លុកដំរី កុយរមាស ឃ្មុំផ្លិតធំៗ ឈើចន្ទន៍ក្រស្នា ក្រវាញ ជ័រចុង បញ្ញើក្អែក (ជីកេង) ប្រេងសំរោង (តៃហ្វងជី)។

ចចាតជាសត្វមួយបែប គេកំរចាប់វាបានណាស់។ នៅក្នុងព្រៃមានស្រះ រឺ ត្រពាំង ហើយនៅក្នុងទឹកនោះមានត្រីជាច្រើន។ សត្វចចាត វាហើរចេញពីព្រៃមកចាប់ត្រីនោះជាអាហារ។ ពួកអ្នកព្រៃគេយកស្លឹកឈើបិទបាំងខ្លួនហើយទៅអង្គុយក្បែរមាត់ទឹក។ គេយកមេចចាតផ្ទាក់មួយដាក់ក្នុងទ្រុង ដើម្បីនឹងបញ្ឆោតចាប់យកចចាតឈ្មោល គឺនៅនឹងដៃគេមានកាន់លប់មួយទៀត រង់ចាំកាលណាចចាតឈ្មោលមកជិត គេគ្របលប់នោះយកវា។ គេធ្វើរបៀបនេះក្នុងមួយថ្ងៃទាល់ល្ងាច ជួលកាលចាប់អិតបានសោះក៏មានដែរ។ ភ្លុកដំរី មានតែអ្នកដែលនៅក្នុងរូងភ្នំឆ្ងាយដាច់ស្រយាលពីគេ ទើបរកបាន។ ដំរីមួយស្រុតស្លាប់ទៅ នៅសល់តែភ្លុកមួយគូប៉ុណ្ណោះ។ ដូច្នេះពាក្យដែលគេធ្លាប់និយាយថា សត្វដំរីក្នុងមួយឆ្នាំប្តូរភ្លុកម្តងនោះមិនពិតទេ។ ភ្លុកណាដែលចាក់នឹងច្បូក រឺ លំពែងបានមក គេទុកជាភ្លុកលេខ១ បើភ្លុកណាដែលគេបានដោយឃើញវាស្រុតស្លាប់ខ្លួនវាភ្លាមគេចាត់ជាភ្លុកល្អលេខ២ បើគេរើសបានដោយដំរីស្លាប់យូរឆ្នាំចោលនៅក្នុងរូងភ្នំ គេចាត់ចាធុនអន់ជាងគេ។

ក្រមួនឃ្មុំ គេរកបានពីដើមឈើចាស់ៗ នៅក្នុងភូមិដែលសត្វឃ្មុំមួយប្រភេទមានចង្កេះស្តួចឆ្មារ ដូចសត្វអង្រ្កងវាធ្វើសំបុក។ អ្នកស្រុកដែលទៅយកឃ្មុំ តាមទូកតូចៗ គេអាចដាក់បានពីរបីពាន់ផ្លិត។ ផ្លិតណាដែលធំជាងគេមានទំងន់ដល់ទៅ ៣០-៤០នាទ្បិ អែផ្លិតណាដែលតូច ក៏មិនតិចជាង១៨ រឺ ១៩នាទ្បិដែរ។

កុយរមាសណាដែលពណ៌ស ហើយមានផ្កា គេចាត់ទុកជាកុយល្អ ហើយបើខ្មៅវិញគេទុកជាកុយអន់មិនសូវល្អ។

ឈើចន្ទន៍ក្រស្នា ដុះនៅក្នុងព្រៃស្បាត ព្រៃស្តុក។ អ្នកស្រុកទៅកាប់យកបានមកដោយពិបាកណាស់ ព្រោះឈើដែលមានខ្លឹម។ ឈើនេះមានសាច់ស្រោយកំរាស់៨ រឺ ៩តិក។ ទោះជាដើមតូចក៏មានសាច់ស្រោយ ៤ រឺ ៥តិកដែរ។

ក្រវា ពួកអ្នកព្រៃគេដាំនៅលើភ្នំ។

ជ័រចុង គឺជាជ័រឈើម្យ៉ាងដែលអ្នកស្រុកនេះគេយកកាំបិតទៅចោះឈើសំរក់ជ័រមុនមួយឆ្នាំ ដល់ឆ្នាំបន្ទាប់មក ទើបគេទៅយកជ័រនោះមក។ បញ្ញើជើងកែង (អ័រគីដេ?) ដុះនៅលើមែកឈើមួយប្រភេទ ដូចគ្នានឹងដើមមនដែលដុះផ្ញើនឹងគេដូច្នេះដែរ ហើយគេកំរនឹងរកបានណាស់

ប្រេងសំរោង គេយកមកពីផ្លែឈើដើមធំមួយប្រភេទដែលមានសន្ឋានដូចផ្លែដូងល្អិតមូលៗ។ នៅក្នុងផ្លែនោះមានគ្រាប់ច្រើនទៀត។ អែម្រេច ដុះព័ទ្ធលើដើមផ្តៅមួយគូ មានពណ៌បៃតងដូលស្មៅ បើនៅខ្ចីពណ៌ក៏ខ្ចី និងរិតតែហិរណាស់ផង។

### ២០. អំពីរបរជំនួញ

អ្នកស្រុកនេះ ពួកស្រីៗប៉ិនជួញដូរណាស់ ហេតុនេះពួកចិនៗ គេរកប្រពន្ធមួយជាមុនសិន ហើយនឹងបានចំនេញច្រើនដោយគេប៉ិនប្រសព្វរកស៊ី។ រាល់ថ្ងៃតែទៅលក់តាំងពីភ្លឺព្រាងៗ ដល់ពេលថ្ងៃត្រង់ទើបឈប់ ហើយពួកនេះគ្មានគ្រែ រឺ ផ្ទះសំរាប់លក់អិវ៉ាន់ទៃ គេច្រើនតែក្រាលវត្ថុ ហាក់ដូចជាកន្ទេលផ្ទាល់នឹងដីតំរៀបគ្នា។ ខ្ញុំលឺគេថា មានបង់ឈ្នួលដីជាលុយអោយពួកមន្ត្រីទៀតផង។

ជំនួញតូចតាច គឺគេជួញស្រូវអង្ករ និង របស់ដែលធ្វើមកពីស្រុកចិន។ បន្ទាប់មក មានលក់ដូរកំនាត់សំពត់ផ្សេងៗ។ ជំនួញធំ គឺគេជួញមាសប្រាក់។ តាមធម្មតា ពួកអ្នកព្រៃ តែឃើញពួកចិនទៅដល់ គេគោរពចិនសំបើមណាស់ ទុកដូចជាបាន

ជួបនឹងព្រះ ហើយក្រាបក្បាលគោពទៀតផង។ លុះដល់ពេលថ្មីៗនេះ ទើបមានការបោកប្រាស់ និង មើលងាយចិន ដោយហេតុមកពីមានមនុស្សទៅច្រើនពេក។

## ២១. ទំនិញចិនដែលគេត្រូវការ

អ្នកស្រុកនេះ គ្មានកើតមាសកើតប្រាក់ទេ គេនឹកឃើញតែមាសមកពីស្រុកចិន គឺមាសប្រាក់ជាផលលេខ១ កំនាត់មានពណ៌ទាំងប្រាំជាលេខ២។ បន្ទាប់មកគេត្រូវការសំនរមកពីស្រុកចេងជីវ ថាំងតែស្នាច់មកពីស្រុកអ៊ូជីវ ចូផ្កាពណ៌មកពីស្រុកជូរជីវ និង ទឹកប្រាក់ជាតិហិង្គុល ក្រដាសសរសេរ ស្ពាន់ធ័រ ថ្មដុត ឈើក្រអូប រិសប៉េកជី ក្រលៀនប្រើស សំពត់សរសៃធ្មៃ សំពត់ហ្វាងឆាវ ឆ័ត្រ ឆ្នាំងដែក ថាសស្ពាន់គជ ម្រ័ក្សណ៍ ក្រាសឈើ ម្ជុល ជាដើម។ ក្រៅពីនេះរបស់ដែលធំៗដូចជាកន្ទេលស្រុកម៉ែងជីវ ដែលគេពេញចិត្តបំផុតគឺ មានសញ្ញារូបម្ទេស តែគេមិនងាយនឹងយកទៅបានទេ។

## ២២. អំពីស្មៅ និង ដើមឈើ

មានដើមទទឹម អំពៅ ផ្កាឈូក ក្រអៅឈូក ផ្លែខេម៉ា ចេក ដូចនៅស្រុកចិនដែរ។ គូលែននិងក្រូចឃ្វិចក៏មានរាងពៅដូចតែជូរ។ ក្រៅពីនេះមានផ្លែឈើព្រៃជាច្រើនដែលប្រទេសចិនយើងមិនធ្លាប់ដែលឃើញ ហើយប្លែកៗទៀតផង។ មានផ្កាជាច្រើនដែលល្អៗ ហើយមានក្លិនក្រអូបណាស់។ ផ្កាដែលដុះនៅក្នុងទឹកក៏មានច្រើនយ៉ាង តែខ្ញុំមិនស្គាល់ថាជាឈ្មោះផ្កាអ្វីទេ។ ចំនែកដើមថោ លី ហេងបួយ សុង ប៉េក សាំ ក្វាយ ឡី ចោ អ៊ាងលីវ គុយឡាង កេកលួយ ឈើប្រភេទអស់នេះគ្មានទេ។ នៅស្រុកនោះ ខែទី១ ក៏មានផ្កាឈូកដែរ។

## ២៣. អំពីសត្វស្លាប

បន្ទាសត្វស្លាប ឃើញមានក្ងោក ចចាត លលក ដែលប្រទេសចិនគ្មាន។ ក្រៅពីនេះដូចជាខ្លែង ក្អែក ត្មាត សេក ចាបស្រុក ត្រដក់ កុក ប្រវឹក និងចាបពួកជាដើម សុទ្ធតែមានទាំងអស់។ សត្វស្លាបដែលស្រុកនេះគ្មាន ដូចជា ហ៊ីងតូវ (ល្វាចេក?) ហាងអេង(ក្ងានព្រៃ) អ៉ឹងអេង (ក្លែងលឿង) តូវអ៊ូ (ត្រចៀកកាំ)..។

## ២៤. អំពីសត្វជើងបួន

សត្វចតុបាទមានរមាស ដំរី គោព្រៃ ដែលប្រទេសចិនគ្មាន។ ក្រៅពីនេះ ខ្លាធំ ខ្លាត្រី ខ្លាឃ្មុំ ជ្រូកព្រៃ ប្រើស ក្តាន់ និង កញ្ជ្រោងជាដើម សុទ្ធតែមានច្រើនណាស់។ សត្វដែលស្រុកនេះគ្មានគឺតោស៊ីងស៊ីង(១) និង អូដ្ឋ។ មាន់ ទា គោ សេះ ជ្រូកនិង ពពែមានច្រើនក្រៃលែង។ តែសេះស្រុកនេះទាបៗណាស់ គោតូចៗក៏មានច្រើនណាស់ដែរ។ សត្វគោនៅរស់ គេហ៊ានជិះ តែដល់វាស្លាប់ទៅគេមិនហ៊ានស៊ី និង មិនហ៊ានយកស្បែកវាទេ គេទុកអោយវារលួយទៅតាមចិត្តចុះ ពីព្រោះវាធ្លាប់ជួយដល់កំលាំងមនុស្សលោក។ វាធ្លាប់តែអូសរទេះ។ ពីដើមមក មិនធ្លាប់មានក្ងានទេ ប៉ុន្តែអិលូវមានហើយ ព្រោះមាននាវាចិនទៅញយៗ គេយកពូជពីស្រុកចិនទៅ។ កន្តុរស្រុកនេះធំៗដុចសត្វឆ្មា ហើយមានកន្តុរមួយមុខទៀតមានក្បាលប្លែកពិសេសធំ ដូចជាក្បាលកូនឆ្កែ។

១ = គឺជាស្វាមាឌធំប៉ុនមនុស្ស ដូចគេធ្លាប់ហៅតាមកុនថា ស្វាគីងកុង

Website : www.khmercenter.ch មណ្ឌលវប្បធម៌ខ្មែរនៅប្រទេសស្វីស
ជាសេវាកម្ម ក្នុងការផ្សាយពុទ្ធសាសនា វប្បធម៌ ជាភាសាខ្មែរ

Khmer Culture Center in Switzerland,
Phone (41)44 3635900 , Fax (41)44 3635900
© 2004 The Switzerland Buddhist Society, (watkhmer) Inc. All rightsreserved.